# អត្ថសញ្ញាគឺមសុខា ?

ភ្នំពេញ ឆ្លើយតបនឹងតម្រូវការអន្តរជាតិ និងសកម្មភាពរបស់លោក រង្ស៊ី ដោយប្រើអត្ថសញ្ញា[1]គឹមសុខា។ វិធានការនេះតម្រង់ទៅគោលដៅពីរយ៉ាង : ទី១គឺ ចង់បង្ហាញអំពីចិត្តជ្រះថ្លារបស់ខ្លួនចំពោះអនុសាសន៍អន្តរជាតិថា ខ្លួនកំពុងជម្រាលទៅរកដំណោះស្រាយចុងក្រោយដែលពួកអន្តរជាតិចង់បាន ; ទី២គឺ ចង់បំបែកថ្នាក់ដឹកនាំ, ពួកសកម្មជន និងអ្នកគាំទ្រ របស់គណបក្សសង្គ្រោះជាតិ។ វិធានការបែបនេះ ពួកយួនកុម្មុយនិស្ត ដែលជាចៅហ្វាយដាច់មុខ របស់របបនៅភ្នំពេញ គេនិយមយកមកអនុវត្ត នៅពេលដែលខ្លួនជួបប្រទះនឹងបញ្ហាចម្បង សំរាប់ពន្យាលពេល ដើម្បីលោតកន្លងបញ្ហា។ តាមមេរៀនរបស់យួន របបនៅភ្នំពេញដឹងច្បាស់ថា ម៉ាស៊ិន នៃសេចក្ដីសម្រេចរបស់អន្តរជាតិ វាមានទម្ងន់ធ្ងន់ ហើយដើរយឺតណាស់, ដូច្នេះ បើសិនជាខ្លួនអាចកៀងគរ សហគមអឺរ៉ុបក្ដី អង្គការសហប្រជាជាតិក្ដី សហរដ្ឋអាមេរិកក្ដី ផ្ដល់ឱ្យខ្លួនមានលទ្ធភាពប្រើពេលវេលាបន្ថែម សំរាប់ឆ្លើយតបនឹងតម្រូវការនោះ ច្បាស់ជាខ្លួនមានជ័យជំនះ ព្រោះសេក្ដីសម្រេចរបស់ពួកនោះ បើបានសម្រេចហើយ គឺត្រូវប្រើពេលវេលាដ៏យូរមួយសំរាប់ ធ្វើការសម្រេចជាថ្មី ហើយ រយៈពេលនោះឯង ដែលខ្លួន ទុកជាអាវុធ

[1] អត្ថសញ្ញា : Paramètre.

## អត្តសញ្ញាកឹមសុខា ?

នយោបាយរបស់ខ្លួនសំរាប់វាយសត្រូវរបស់ខ្លួន។ រីឯ ជម្រើសយក កឹម សុខា ជានុយទាក់ទាញក្រុមរបស់គាត់ឱ្យបែកពី សម រង្ស៊ី វិញ វានៅក្នុងគោលដៅទី១ផង និងរំខានពេលវេលា ដល់សកម្មភាពវាយលុកនយោបាយរបស់លោក រង្ស៊ី ផង ព្រោះចង់ឬមិនចង់ ទោះបី កឹម សុខា គាត់ បង្ហាញពីការមិនពេញចិត្តរបស់គាត់ ចំពោះសេចក្តីសំរេច របស់តុលាការ បន្ធូបន្ថយលក្ខខណ្ឌឃុំឃាំងគាត់ក៏ដោយ តែសកម្មភាព របស់អ្នកគាំទ្រគាត់ នៅក្រៅប្រទេស មិនមានសាមគ្គីភាពជាមួយ សម រង្ស៊ី ប៉ុន្មានឡើយ ដែលវានាំបង្ហាញ នូវរូបភាព នៃការបែកបាក់ផ្ទៃក្នុងរបស់គណបក្សសង្គ្រោះជាតិ។ រូបភាពនេះឯង ដែលរបបនៅភ្នំពេញ គេចង់កេងចំណេញ។ ដូច្នេះ កឹម សុខា ចង់ឬមិនចង់ វាមានរូបភាព ជាកូនរែក របស់របបនៅភ្នំពេញ ដើម្បីប្រឆាំងនឹង សម រង្ស៊ី។ សួរថា តើ សម រង្ស៊ី និង កឹម សុខា នៅតែជាមនុស្សតែមួយ ដូចសេចក្តីសំអាងរបស់ រង្ស៊ី ដែរឬទេនៅក្នុងវិញ្ញាសា នៃការតស៊ូនយោបាយក្នុងអនាគតដ៏ខ្លីខាងមុខនេះ ដែលជាជម្រើស នៃយុទ្ធសាស្ត្ររបស់ រង្ស៊ី។ នៅលើចំណុចនេះឯង ការសង្ស័យនៅតែមានទាំងអស់នៅឡើយ បើយោងតាម បទពិសោធន៍ពីអតីតកាល ដែលរបបនៅភ្នំពេញ គេឱ្យឈ្មោះថា « ឈ្នះឈ្នះ »៕